**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**និយ័តករអាជីវកម្មអចលនវត្ថុ និងបញ្ចាំ**

ថ្ងៃ សុក្រ ៩រោច ខែ ភទ្របទ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០២៣

# សេចក្តីជូនដំណឹង

យោងប្រសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់បំផុតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** និយ័តករអាជីវកម្មអចលនវត្ថុ និងបញ្ចាំ (**ន.អ.ប.**) សូមជម្រាបជូនដល់អតិថិជនទាំងអស់ដែលបានទិញលំនៅឋាន ឬអគារសហកម្មសិទ្ធិ (ខុនដូ) ពីគម្រោងអភិវឌ្ឍអចលនវត្ថុ ហើយត្រូវបានម្ចាស់គម្រោងអភិវឌ្ឍអចលនវត្ថុធ្វើការរឹបអូសយកវិញនូវលំនៅឋាន ឬអគារសហកម្មសិទ្ធិ (ខុនដូ) ដោយសារមានបញ្ហាខកខានក្នុងការបង់ប្រាក់ សូមជូនដំណឹងមក **ន.អ.ប.** ជាបន្ទាន់ ដើម្បីធ្វើការសម្របសម្រួលជាមួយម្ចាស់គម្រោង។ អតិថិជនអាចធ្វើការទំនាក់ទំនងតាមរយៈទូរស័ព្ទ ឬតាមតេលេក្រាមលេខ÷ ០១២ ៣៩៣-៧២៧ /០៩៩ ៩៨០ ៤៩៩ /០៦៩ ៥១៧ ១៨៦ ឬអញ្ជើញមកដោយផ្ទាល់នៅអគារអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ដែលមានអាស័យដ្ឋាននៅអគារ ១៦៨F ជាន់ទី៧ ផ្លូវលេខ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។ ជាមួយគ្នានេះ **ន.អ.ប.** នឹងតាមដានព័ត៌មានពាក់ព័ន្ធនឹងកិច្ចការនេះតាមបណ្តាញសង្គមផងដែរ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមអតិថិជនទាំងអស់មេត្តាជ្រាបជាព័ត៌មាន និងចូលរួមសហការ។

**និយ័តករអាជីវកម្មអចលនវត្ថុ និងបញ្ចាំ**

អគារ១៦៨F (ជាន់ទី៧) ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កម្ពុជា
Building 168F (7th Floor), Street 598, Sangkat Chraing Chamreh 1, Khan Russey Keo, Phnom Penh, Cambodia.
ទូរស័ព្ទ (+៨៥៥) ៧៨ ២៦៦ ២៦៨
Phone (+855) 78 266 268